**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

លេខ : ៧៩៨៧ អ.ជ.ក.អក.អប

## សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា**មានកិត្តិយស សូមទូលថ្វាយ និងជម្រាបជូន សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលជាអតិថិជនរបស់អគ្គិសនីកម្ពុជាជ្រាបថា : ដើម្បីអនុវត្តការងារជួសជុល ថែទាំ និងផ្លាស់ប្តូរបរិក្ខារប្រព័ន្ធបណ្តាញចែកចាយ អគ្គិសនីកម្ពុជានឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ភ្លើងមួយចំនួនទៅតាមពេលវេលា និងទីកន្លែងដោយមូលហេតុដូចខាងក្រោម :

១. ថ្ងៃព្រហស្បតិ៍ទី០៣ ខែមេសា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉ោ០០ ដល់ម៉ោង១៦ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅភូមិដើមគរ ភូមិព្រែកតាសេក ក្នុងសង្កាត់ព្រែកតាសេក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីកែលម្អខ្សែបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

២. ថ្ងៃសុក្រទី០៤ ខែមេសា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ភ្លើងលេខ P1035 ស្ថិតនៅភូមិត្រពាំងឈូក ក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីកែលម្អខ្សែបណ្តាញផ្គត់ផ្គង់អគ្គិសនី ។

៣. ថ្ងៃសៅរ៍ទី០៥ ខែមេសា ឆ្នាំ២០១៤ ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៧ម៉០០ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនីនៅ (១)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤១ ចាប់ពីភូមិព្នៅ ហូតដល់ភូមិអង្គ ក្នុងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និង (២)តំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវវែងស្រេង ចាប់ពីភូមិឫស្សី រហូតដល់មុខទីតាំងសួនឧស្សាហកម្មវឌ្ឍនៈ ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្គលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវវែងស្រេង ។

៤. ថ្ងៃអាទិត្យទី០៦ ខែមេសា ឆ្នាំ២០១៤ នឹងផ្អាកការផ្គត់ផ្គង់អគ្គិសនី (១)ចាប់ពីម៉ោង០៩ម៉០០ ដល់ម៉ោង១៣ម៉០០ នៅតំបន់ភ្លើងមួយចំនួនដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ១ ចាប់ពីសង្កាត់វាលស្បូវ ហូតដល់សង្កាត់ព្រែកឯង ក្នុងខណ្ឌមានជ័យ និង (២)តំបន់ភ្លើងលេខ P451 ស្ថិតនៅតាមបណ្តោយផ្លូវវែងស្រេង ក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដើម្បីតម្លើងបរិក្ខារ និងរុះរើគន្លងខ្សែបណ្តាញបង្គលក្ខណៈដល់ការដ្ឋានពង្រីកផ្លូវវែងស្រេង ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជ្រាបជាព័ត៌មាន និងសូមអធ្យាស្រ័យចំពោះការដាច់ចរន្តអគ្គិសនីនេះ ដោយអនុគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី...០១....ខែ.មេសា..ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**